# អ្វីដែលអ្នកគួរតែស្វែងយល់អំពី ជំងឺអុតស្វា

ជំងឺអុតស្វាគឺជាប្រភេទជំងឺឆ្លងមួយដែលបង្កឡើងដោយមេរោគអុតស្វា។ បុគ្គលណាម្នាក់ដែលមានទំនាក់ទំនងជិតស្និទ្ធដោយផ្ទាល់ជាមួយនឹងអ្នកដែលមានជំងឺអុតស្វា គឺប្រឈមនឹងហានិភ័យ។

## ជាទូទៅរោគសញ្ញានានាចាប់ផ្ដើមកើតមានឡើងក្នុងចន្លោះពេលពី 5 ទៅ 21 ថ្ងៃបន្ទាប់ពីការប៉ះពាល់ទៅនឹងមេរោគរួច

### រោគសញ្ញាសំខាន់

**កន្ទួលរមាស់**



កន្ទួលរមាស់នេះ អាចៈ

- មើលទៅដូចជាឡើងដុំពក មុន (លើស្បែក) ពងបែក ដំបៅ ឬមានឡើងក្រមរ
- ចេញនៅគ្រប់ទីកន្លែងនៅលើរាងកាយ រួមទាំងនៅលើប្រដាប់ភេទ ទ្វារធំ មាត់ ដៃ និងមុខផងដែរ
- ចេញនៅកន្លែងតែមួយ ឬអាចរីករាលដាលពាសពេញរាងកាយ
- មានការរមាស់ ឬឈឺចាប់ (ជាពិសេសប្រសិនបើកើតមាននៅខាងក្នុងមាត់ ឬទ្វារធំ)

### រោគសញ្ញាផ្សេងទៀត

**រោគសញ្ញាដែលដូចគ្នាទៅនឹងជំងឺគ្រុនផ្ដាសាយធំ (flu)**



គ្រុនក្ដៅ/ គ្រុនរងា



អស់កម្លាំង ឈឺសាច់ដុំ និងឈឺក្បាល



ហើមកូនកណ្ដុរ

- រោគសញ្ញាដែលដូចគ្នាទៅនឹងជំងឺគ្រុនផ្ដាសាយធំទាំងឡាយអាចលេចឡើងក្នុងចន្លោះពេលពី 1 ទៅ 4 ថ្ងៃមុនពេលកន្ទួលរមាស់ចាប់ផ្ដើមកើតមាន ឬក្រោយពេលកន្ទួលរមាស់កើតមានហើយ
- មិនមែនមនុស្សគ្រប់គ្នានឹងកើតមានរោគសញ្ញាទាំងនេះទេ

## របៀបដែលជំងឺអុតស្វាវីករាលដាល

ជំងឺអុតស្វាត្រូវបានស្គាល់ថាជាជំងឺដែលអាចរីករាលដាលតាមរយៈទំនាក់ទំនងជិតស្និទ្ធ ព្រមទាំងការប៉ះពាល់ដោយស្និទ្ធស្នាល និង/ឬទំនាក់ទំនងក្នុងរយៈពេលយូរផងដែរ ដែលរួមមាន៖

- ការប៉ះពាល់ស្បែកនឹងស្បែកដោយផ្ទាល់ជាមួយនឹងកន្ទួលរមាស់ ក្រមរ ឬដំបៅក្នុងអំឡុងពេលរួមភេទ ហើយនិងការប៉ះពាល់ដោយស្និទ្ធស្នាលផ្សេងទៀតដូចជាការថើប ការម៉ាស្សា និងការឱបដោយថ្នាក់ថ្នម (cuddling) ផងដែរ។
- ការប៉ះពាល់ជាមួយនឹងរបស់របរ និងសាច់ក្រណាត់នានា (ដូចជាសម្លៀកបំពាក់ កម្រាលពូក ឬស្រោមខ្នើយ កន្សែងជូតខ្លួន ឬប្រដាប់លេងពេលរួមភេទ [sex toys]) ដែលបានប្រើប្រាស់រួចដោយអ្នកដែលមានជំងឺអុតស្វា ហើយមិនទាន់បានលាងសម្អាត ឬបោកគក់សម្អាត។
- ការប៉ះពាល់ជាមួយនឹងសារធាតុរាវផ្សេងៗដែលចេញតាមផ្លូវដង្ហើម។ ចំណុចនេះអាចកើតមានឡើងក្នុងអំឡុងពេលមានទំនាក់ទំនងទល់មុខដោយផ្ទាល់ក្នុងរយៈពេលយូរ ឬការប៉ះពាល់ដោយស្និទ្ធស្នាល។

បុគ្គលម្នាក់ដែលមានជំងឺអុតស្វា អាចចម្លងទៅកាន់អ្នកផ្សេងទៀតបាន គិតចាប់តាំងពីពេលដែលចាប់ផ្តើមកើតមានរោគសញ្ញានានា រហូតដល់ពេលកន្ទួលរមាស់បានជាសះស្បើយ ហើយក្រមរដំបៅបានរបកជ្រុះអស់ និងមានស្រទាប់ស្បែកថ្មីដុះឡើងវិញ។ ជាធម្មតា ត្រូវការរយៈពេលចន្លោះពី 2 ទៅ 4 សប្តាហ៍។

បុគ្គលដែលមានផ្ទៃពោះ ហើយដែលមានផ្ទុកជំងឺអុតស្វា អាចចម្លងមេរោគនេះបន្តទៅទារកនៅក្នុងផ្ទៃរបស់ពួកគេបាន។

**ជំងឺអុតស្វាមិនរីករាលដាល** តាមរយៈការសន្ទនាជាធម្មតា ឬក៏តាមរយៈការដើរក្បែរអ្នកដែលមានជំងឺនេះទេ។

**ការចាក់ថ្នាំបង្ការ** គឺមានផ្តល់ជូនអ្នកដែលប្រឈមនឹងហានិភ័យខ្ពស់ជាងមុន រួមមានទាំងអ្នកដែលបានប៉ះពាល់ទៅនឹងជំងឺអុតស្វាផងដែរ។

**ការព្យាបាលដោយប្រើប្រាស់ថ្នាំប្រឆាំងនឹងមេរោគ (antiviral)** គឺមានផ្តល់ជូនអ្នកដែលមានជំងឺអុតស្វាកម្រិតធ្ងន់ធ្ងរ ឬអ្នកដែលប្រឈមនឹងហានិភ័យនៃការកើតមានជំងឺអុតស្វាកម្រិតធ្ងន់ធ្ងរ។

សម្រាប់ព័ត៌មានបន្ថែម សូមពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់អ្នក ឬចូលទៅកាន់គេហទំព័រ ph.lacounty.gov/Monkeypox។

### សូមទាក់ទងទៅគ្រូពេទ្យរបស់អ្នក

ភ្លាមៗ ប្រសិនបើអ្នកមានកន្ទួលរមាស់ ឬដំបៅថ្មី ដែលខុសប្រក្រតី។ ការធ្វើបែបនេះមានសារៈសំខាន់ជាពិសេស ប្រសិនបើអ្នកបានប៉ះពាល់ទៅនឹងនរណាម្នាក់ដែលមានជំងឺ ឬសង្ស័យថាមានជំងឺអុតស្វា។

### ប្រសិនបើអ្នកមិនមានគ្រូពេទ្យប្រចាំខ្លួនទេ៖

- សូមទូរស័ព្ទទៅនាយកដ្ឋានសុខភាពសាធារណៈតាមរយៈលេខ 1-833-540-0473 (មានផ្តល់សេវាកម្មជូនចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8:30 យប់ ជារៀងរាល់ថ្ងៃ) ឬ
- សូមទៅកាន់ គ្លីនិកផ្នែកសុខភាពផ្លូវភេទរបស់សុខភាពសាធារណៈ មួយដែលនៅជិតអ្នក។

**សូមស្កេនកូដ QR នេះ ដើម្បីស្វែងរកទីតាំងមួយ**